ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីដាក់ឲ្យប្រើប្រាស់ក្រមស្តីពីការប្រតិបត្តិសេវាធនាគារ

នៅសណ្ឋាគារIntercontinental
ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥

សូមគោរព ៖

- អ្នកឧកញ៉ា ពុង ឃាវសែ ប្រធានសមាគមធនាគារនៅកម្ពុជា
  និងជាប្រធានក្រុមប្រឹក្សាភិបាល ធនាគារកាណាឌីយ៉ា ក.អ
- លោកឧកញ៉ាបណ្ឌិត ប៊ុន មុន្នី ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
  និងជាប្រធាននាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមក្នុងពិធីដាក់ឲ្យប្រើប្រាស់ក្រមស្តីពីការប្រតិបត្តិសេវាធនាគារ ដែលជាសមិទ្ធផលថ្មីមួយបន្ថែមទៀតរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជានាពេលនេះ ។ ក្នុងនាមធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមាគមធនាគារ សមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងក្រុមការងារបច្ចេកទេស ដែលបានចងក្រងនូវក្រមនេះឡើង ដើម្បីទុកជាវិធានសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់អនុវត្ត ។

ក្រមនេះគឺជាការរួមចំណែកដ៏សំខាន់ក្នុងការកសាងទំនុកចិត្តរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុមកលើប្រព័ន្ធធនាគារនៅកម្ពុជា ។ ការកសាងនូវទំនុកចិត្តគឺត្រូវការពេលវេលាដ៏យូរអង្វែង ប៉ុន្តែប្រសិនបើមានបច្ច័យអាក្រក់ណាមួយកើតឡើងមកលើប្រព័ន្ធធនាគារយើងវិញ វានឹងបណ្តាលឲ្យសាធារណជនងាយនឹងបាត់បង់ទំនុកចិត្តក្នុងរយៈពេលមួយដ៏ខ្លី ។ វឌ្ឍនភាពនៃប្រព័ន្ធធនាគារនៅកម្ពុជារហូតដល់បច្ចុប្បន្ននេះគឺកើតឡើងដោយសារទំនុកចិត្តរបស់សាធារណជន និងអ្នកវិនិយោគទាំងក្នុងនិងក្រៅប្រទេស ។ ដូច្នេះ យើងទាំងអស់គ្នាត្រូវខិតខំថែរក្សា និងបន្តពង្រឹងកិច្ចសហការល្អបន្ថែមទៀតដើម្បីរក្សាឲ្យបាននូវសមិទ្ធផលដែលទទួលបានដូចសព្វថ្ងៃ ។ ខ្ញុំសង្ឃឹមថា តាមរយៈការចងក្រងក្រមនេះគឺដើម្បីការពារដល់អតិថិជន មានសង្គតភាពក្នុងប្រតិបត្តិការ បង្កើនតម្លាភាព បង្កើតទំនាក់ទំនងរវាងអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនិងគ្រឹះស្ថានហិរញ្ញវត្ថុដោយមិនលំអៀង បង្កើននូវជំនឿទុកចិត្តរបស់សាធារណជន និងជំរុញការអនុវត្តនូវវប្បធម៌សាជីវកម្មបែបសមធម៌ក្នុងការប្រតិបត្តិការងាររបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ថា វិស័យធនាគារនៅកម្ពុជារក្សាបាននូវស្ថិរភាព និងអត្រាកំណើនសមស្រប ។ ក្នុងគោលដៅរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាកត្តាមូលដ្ឋានសម្រាប់ជំរុញកំណើននិងបង្កើតការងារ ធនាគារជាតិនៃកម្ពុជាបានរក្សាស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព តាមរយៈការអនុវត្តគោលនយោបាយ រូបិយវត្ថុដែលមានភាពទន់ភ្លន់និងប្រុងប្រយ័ត្នខ្ពស់ ស្របតាមការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។ ជាលទ្ធផលអត្រាអតិផរណាក្នុងឆ្នាំ២០១៤ មានអត្រាក្រោម ៥% ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ខណៈដែលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានស្ថិរភាពក្នុងរង្វង់ ៤.០០០ រៀល ។

ទន្ទឹមនឹងការបន្តរីកចម្រើនរឹងមាំនៃសេដ្ឋកិច្ច វិស័យធនាគារនៅកម្ពុជាក៏បន្តភាពរីកចម្រើនជាលំដាប់ ។ ការរីកចម្រើននៃវិស័យធនាគារនៅកម្ពុជាអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗមួយចំនួនដូចជា ការកើនឡើងនៃភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុដែលបន្តកើនឡើងរហូតដល់ ៦៣% និងកំណើននៃទ្រព្យសកម្មមានប្រមាណ ២៨% ស្របពេលដែលប្រាក់បញ្ញើ និងឥណទានបានកើនឡើងប្រមាណ ៣១% ដូចគ្នា ។ ចំណែកឯវិស័យមីក្រូហិរញ្ញវត្ថុវិញបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍនៅតំបន់ជនបទ និងបានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួននៅទូទាំងប្រទេសរហូតដល់តំបន់ជនបទ ។ សកម្មភាពប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តកើនឡើងគួរឲ្យកត់សំគាល់ តួយ៉ាងកំណើននៃទ្រព្យសកម្មបានកើនឡើងប្រមាណ ៦០% ឬ ស្មើនឹង ១៤% នៃទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ ចំណែកឯឥណទានមានកំណើនប្រមាណ ៥០% ខណៈដែលប្រាក់បញ្ញើសម្រាប់គ្រឹះស្ថានមីក្រូទទួលប្រាក់បញ្ញើបានកើនឡើងទ្វេដង ។

កន្លងមកមានក្រុមមួយចំនួនបង្ហាញខ្លួនជាអង្គការមិនមែនរដ្ឋាភិបាល ជាសមាគមសប្បុរសធម៌ ឬ ជាសប្បុរសជនបានធ្វើការឱ្យខ្ចីប្រាក់តាមជនបទ និងទីប្រជុំជន ហើយចាត់ខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ សកម្មភាពឱ្យខ្ចីប្រាក់ មិនគ្រាន់តែគ្មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាប៉ុណ្ណោះទេ ថែមទាំងយកការប្រាក់ខ្ពស់ និងមិនមានតម្លាភាព ។ ឆ្លើយតបនឹងសភាពការណ៍នេះ កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដើម្បីជម្រាបជូនសាធារណជនឱ្យយល់ច្បាស់ពីបញ្ហានេះ ។ អង្គការក្រៅរដ្ឋាភិបាល សមាគមសប្បុរសធម៌ ឬ សប្បុរជនទាំងនោះគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនស្របច្បាប់និងពុំកាន់កាប់ដោយរដ្ឋឡើយ ពោលគឺជាគ្រឹះស្ថានដែលកាន់កាប់ដោយឯកជនសុទ្ធសាធ ។ ទន្ទឹមនឹងនោះ ក៏តម្រូវឱ្យគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងចុះបញ្ជី ត្រូវវិភាគវាយតម្លៃអំពីសមត្ថភាពសងប្រាក់របស់អ្នកសុំខ្ចី ហើយត្រូវមានការទទួលខុសត្រូវខ្ពស់ក្នុងការបង្ហាញព័ត៌មាននិងលក្ខខណ្ឌផ្សេងៗពាក់ព័ន្ធនឹងការខ្ចីប្រាក់ឱ្យបានច្បាស់លាស់ ជូនដល់អ្នកសុំខ្ចីប្រាក់ ។

ដូច្នេះ ការចុះហត្ថលេខាលើក្រម ស្តីពីការប្រតិបត្តិសេវាធនាគារ ថ្ងៃនេះ គឺជាសក្ខីកម្មថ្មីមួយទៀត ដែលបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា សុឆន្ទៈ និង សាមគ្គីភាព

របស់វិស័យធនាគារនិងហិរញ្ញវត្ថុជាផ្លូវការ ក៏ដូចជាអាជ្ញាធរ ក្នុងការការពារផលប្រយោជន៍របស់អតិថិជន ឱ្យកាន់តែប្រសើរឡើងមួយកម្រិតថែមទៀត ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

កន្លងមក ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ដល់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុជាប្រចាំតាមរយៈការពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា ការពង្រឹងគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ ការដាក់ឲ្យអនុវត្តប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាដើម ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់ការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ ។

តាមរយៈខ្លឹមសារនៃក្រមបានបង្ហាញពីយន្តការនៃការការពារដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដោយបែងចែកជាពីរដំណាក់កាល ទី១. ការផ្តល់សិទ្ធិដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងការតវ៉ាចំពោះការបម្រើសេវារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលខ្លួនមិនពេញចិត្តនៅគ្រឹះស្ថាននោះផ្ទាល់ និង ទី២. បើអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុមិនពេញចិត្តចំពោះដំណោះស្រាយក្នុងដំណាក់កាលទី១ គាត់មានសិទ្ធិប្តឹងតវ៉ាដល់គណកម្មការដោះស្រាយវិវាទដែលមានតំណាងមកពីធនាគារជាតិនៃកម្ពុជា តំណាងមកពីសមាគមធនាគារ និងតំណាងមួយរូបទៀតជាបុគ្គលឯករាជ្យ ។ ក្រមនេះជាឯកសារមានភាពទន់ភ្លន់ដែលអាចធ្វើបច្ចុប្បន្នកម្មបានក្នុងពេលសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងវឌ្ឍនភាពនៃវិស័យហិរញ្ញវត្ថុ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ការអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមស្តីពីការប្រតិបត្តិសេវាធនាគារនឹងទទួលបានលទ្ធផលកាន់តែល្អប្រសើរ ដើម្បីបន្តអភិវឌ្ឍន៍វិស័យធនាគារនិងហិរញ្ញវត្ថុដែលមានភាពប្រកួតប្រជែង សមាហរណកម្ម និងមានប្រសិទ្ធភាពក្នុងគោលដៅរក្សានូវទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា ។ ខ្ញុំសូមលើកទឹកចិត្តឲ្យគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ សូមផ្តល់ការគាំទ្រ និងសូមយកចិត្តទុកដាក់ចូលរួមអនុវត្តក្រមនេះ ឲ្យបានទទួលជោគជ័យ និងប្រសិទ្ធភាពខ្ពស់ ។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ព្រមទាំងក្រុមគ្រួសារ សូមមានសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច។ ខណៈដែលបុណ្យចូលឆ្នាំប្រពៃណីចិន-វៀតណាមខិតជិតមកដល់ ខ្ញុំសូមជូនពរអស់លោក-លោកស្រី សិរីសួស្តីឆ្នាំថ្មីទាំងអស់គ្នា ។

ជាទីបញ្ចប់ មុននឹងប្រកាសដាក់ឲ្យអនុវត្តក្រមស្តីពីការប្រតិបត្តិសេវាធនាគារនេះ ខ្ញុំសូមលើកនូវឱវាទរបស់ព្រះសម្មាសម្ពុទ្ធ មុនពេលដែលព្រះអង្គចូលបរិនិពាន្ទ ព្រះអង្គបានមានពុទ្ធដិការទូន្មានថា "ចូលអ្នកទាំងឡាយ សម្រេចនូវករណីយកិច្ចទាំងឡាយដោយសេចក្តីមិនប្រមាថចុះ" ។

ខ្ញុំសូមប្រកាសដាក់ឲ្យអនុវត្ត ក្រមស្តីពីការប្រតិបត្តិសេវាធនាគារ ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**